# អនុសាសន៍

# នៃវេទិកាអាស៊ានលើកទី៧ស្តីពីពលកម្មទេសន្តរប្រវេសន៍

# ថ្ងៃទី២០ ដល់២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ក្រុងណៃ ព្យី តាវ មីយ៉ាន់ម៉ា

វេទិការអាស៊ានលើកទី៧ស្តីពីពលកម្មទេសន្តរប្រវេសន៍ដែលមានប្រធានបទថា "ឆ្ពោះទៅកាន់សហគមន៍អាស៊ាននៅឆ្នាំ២០១៥ដោយមានការធ្វើឲ្យប្រសើរឡើងនូវវិធានការដើម្បីការពារ និងជំរុញសិទ្ធិពលករទេសន្តរប្រវេសន៍ "ត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី២០ដល់២១ខែវិច្ឆិកាឆ្នាំ២០១៤នៅក្រុងណៃ ពៀ តាវ នៃប្រទេសមីយ៉ាន់ម៉ា។ អ្នកតំណាងរដ្ឋាភិបាល អ្នកតំណាងអង្គការនិយោជក និងអង្គការកម្មករ និងអង្គការសង្គមស៊ីវិលមកពីរដ្ឋជាសមាជិកអាស៊ាន លេខាធិការដ្ឋានអាស៊ាន អង្គការអន្តរជាតិខាងការងារ (ILO) អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) អង្គការសហប្រជាជាតិទទួលបន្ទុកស្ត្រីភេទ សហភាពនិយោជកអាស៊ាន (ACE) ក្រុមប្រឹក្សាសហជីពអាស៊ាន (ATUC) ក្រុមប្រឹក្សាសហជីពសេវាកម្មនិយោជិតអាស៊ាន (ASETUC) និងក្រុមការងារដើម្បីពលករទេសន្តរប្រវេសន៍អាស៊ាន (TFAMW) បានចូលរួមក្នុងវេទិការនេះ។

វេទិការអាស៊ានលើកទី៧ស្តីពីពលកម្មទេសន្តរប្រវេសន៍ត្រូវបានប្រារព្ធធ្វើឡើងជាការអនុវត្តន៍សេចក្តីប្រកាសអាស៊ានស្តីពីកិច្ចការពារ និងជំរុញសិទ្ធិពលករទេសន្តរប្រវេសន៍ កម្មវិធីការងារនៃរដ្ឋមន្ត្រីការងារអាស៊ានឆ្នាំ២០១០ដល់២០១៥ និងឯកសារគំរូសហគមន៍វប្បធម៌ និងសង្គមអាស៊ាន (ASCC) (ជូរសកម្មភាព C.2 ii) ដែលអំពាវនាវឲ្យមានវេទិការស្តីពីពលកម្មទេសន្តរប្រវេសន៍អាស៊ានយ៉ាងទៀងទាត់មួយជាវេទិការសំរាប់ការពិភាក្សាយ៉ាងទូលំទូលាយស្តីពីបញ្ហាពលកម្មទេសន្តរប្រវេសន៍នៅក្រោមការឧបត្ថម្ភរបស់គណៈកម្មាធិការអាស៊ានទទួលបន្ទុកការអនុវត្តន៍សេចក្តីប្រកាសអាស៊ានស្តីពីកិច្ចការពារ និងជំរុញសិទ្ធិពលករទេសន្តរប្រវេសន៍ (ACMW) ដែលរាយការណ៍ជូនកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខាងការងារអាស៊ាន (SLOM)

ដោយមានការណែនាំដោយបទដ្ឋានពលកម្មអន្តរជាតិពាក់ព័ន្ធ អ្នកចូលរួមទាំងអស់បានព្រមព្រៀងគ្នាផ្តល់អនុសាសន៍ឲ្យមានវិធានការខាងក្រោមនេះដើម្បីជំរុញ និងការពារសិទ្ធិ និងដោះស្រាយភាពងាយរងគ្រោះជាក់លាក់របស់ពលករទេសន្តរប្រវេសន៍ទាំងស្ត្រី និងបុរសនៅក្នុងតំបន់ជាពិសេសពាក់ព័ន្ធនឹងការអនុវត្តន៍ការប្តេជ្ញាចិត្តនៃរដ្ឋជាសមាជិកអាស៊ានក្នុងមាត្រាទី៨ និងទី១៣នៃសេចក្តីប្រកាសអាស៊ានស្តីពីកិច្ចការពារ និងជំរុញសិទ្ធិពលករទេសន្តរប្រវេសន៍។

**ការជំរុញឲ្យមានកិច្ចគាំពារការងារដោយយុត្តិធម៌ និងសមស្រប ការបើកប្រាក់ឈ្នួល និងការទទួលបានល័ក្ខខ័ណ្ឌការងារ និងល័ក្ខខ័ណ្ឌរស់នៅសមរម្យសំរាប់ពលករទេសន្តរប្រវេសន៍:**

១. កិច្ចសន្យាការងារគួរមានបទដ្ឋានស្របតាមច្បាប់ការងារជាតិ ដោយផ្អែកលើបទដ្ឋានពលកម្មស្នូល និងអនុលោមតាមមាត្រាទី២២នៃអនុសាសន៍នៃអង្គការ ILO (លេខ៨៦ ឆ្នាំ១៩៤៩)អំពីការធ្វើទេសន្តរប្រវេសន៍រកការងារ។

២. បទដ្ឋានកិច្ចសន្យាការងារ គួរចែងយ៉ាងច្បាស់អំពីអាណត្តិ និងល័ក្ខខ័ណ្ឌការងារ សិទ្ធិ និងការទទួលខុសត្រូវរបស់ពលករ និងពលការនី និងនិយោជក នៅក្នុងវិស័យងាយរងគ្រោះ និងពិបាកទៅជួប ដូចជានេសាទ ការងារផ្ទះ និងការងារសំណង់ ហើយត្រូវមានយន្តការដោះស្រាយបណ្តឹងសារទុក្ខ ពោលគឺមានព័ត៌មានទំនាក់ទំនងនិងប្រពន្ធផ្នែកច្បាប់ ដើម្បីដាក់ពាក្យបណ្តឹង។ កិច្ចសន្យាការងារ គួរត្រូវបានចែងជាភាសាពលករទេសន្តរប្រវេសន៍ ហើយត្រូវចុះហត្ថលេខាដោយនិយោជក និងពលករមុនពេលចេញដំណើរ។ គួរផ្តល់ច្បាប់ចម្លងកិច្ចសន្យាការងារមួយច្បាប់ទៅឲ្យពលករទេសន្តរប្រវេសន៍។

៣. ក្របខ័ណ្ឌ/គោលការណ៍ណែនាំអាស៊ានអំពីបទដ្ឋានកិច្ចសន្យាការងារ គួរត្រូវបានបង្កើតឡើងដោយមានការផ្តល់មតិយោបល់ពីប្រទេសដើមកំណើត និងប្រទេសទីដៅ ដៃគូសង្គម អង្គការសង្គមស៊ីវិល និងសមាគមពលករទេសន្តរប្រវេសន៍ និងដោយពិចារណាលើច្បាប់ការងារដែលនៅជាធរមានរបស់រដ្ឋជាសមាជិកអាស៊ាន។

៤. គួរលុបបំបាត់ចោលនូវការជំនួសកិច្ចសន្យាការងារ និងការចេញកិច្ចសន្យាការងារក្រោមបទដ្ឋាន។ និយោជកដែលមិនប្រតិបត្តិតាមគួរត្រូវបានដាក់ទោសទណ្ឌ និងត្រូវកត់ត្រាក្នុងមូលដ្ឋានទិន្នន័យនៃរដ្ឋជាសមាជិកអាស៊ានដោយអនុលោមតាមបទបញ្ញត្តិ និងច្បាប់ជាតិ។ នៅពេលដែលកិច្ចសន្យាការងារត្រូវបានចេញដោយភាគីទី៣ដែលអនុញ្ញាត្តិដោយច្បាប់ ត្រូវមានការត្រួតពិនិត្យឃ្លាំមើលយ៉ាងជិតដល់ដើម្បីធានាថាឆ្លើយតបទៅតាមបទដ្ឋានដែលតម្រូវ។

៥. រដ្ឋាភិបាលគួរចាត់វិធានការ និងបែងចែកធនធានដើម្បីការពារ និងជំរុញសិទ្ធិពលករទេសន្តរប្រវេសន៍ ដោយរួមមានការធ្វើអធិការកិច្ចការងារយ៉ាងទៀងទាត់ទាំងក្នុងវិស័យ និងកន្លែងការងារងាយរងគ្រោះ និង ពិបាកចូលទៅជួប (ឧទាហរណ៍ នេសាទ ការរុករករ៉ែ ព្រៃឈើ កសិកម្ម និងការងារផ្ទះ។ រដ្ឋាភិបាលត្រូវផ្តល់ការបណ្តុះបណ្តាលដល់អ្នកធ្វើអធិការកិច្ចការងារ និងបង្កើត ក្រុម

ការងារពហុវិស័យដើម្បីធ្វើអធិការកិច្ចការងារ។ អនុសញ្ញាលេខ១៨៩ នៃអង្គការ ILO និងអនុសាសន៍លេខ២០១ផ្ដល់គោលការណ៍ណែនាំអំពីការធ្វើអធិការកិច្ចការងារលើការងារផ្ទះ។

៦. សុខភាព និងសុវត្ថិភាពការងារ (OSH) គួរត្រូវបានធ្វើឲ្យប្រសើរឡើងតាមរយៈការបណ្តុះបណ្តាល OSH និងការផ្ដល់សំភារៈការពារខ្លួន (នៅកន្លែងដែលអាចអនុវត្តបាន) ដោយនិយោជកនៅការដ្ឋាននៅពេលដែលពលករទេសន្តរប្រវេសន៍មកដល់ និងផ្ដល់យ៉ាងទៀងទាត់នៅពេលបន្ទាប់ ក៏ដូចជារក្សាទុកទិន្នន័យ OSH និងការវិភាគសំរាប់ការប្រើប្រាស់។

៧. គួរបង្កើតសេវាច្រកចេញចូលតែមួយ និងមណ្ឌលធនធានធនទេសន្តរប្រវេសន៍នៅក្នុងរដ្ឋជាសមាជិកអាស៊ានទាំងអស់ ហើយត្រូវធ្វើសមាហរណកម្មនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ដើម្បីធានាឲ្យមានយន្តការគាំពារកាន់តែប្រសើរឡើងសំរាប់ពលករទេសន្តរប្រវេសន៍ទាំងស្ត្រី និងបុរស។ គួរបង្កើតឲ្យមានទូរស័ព្ទបន្ទាន់ ២៤ ម៉ោងជាភាសាពលករទេសន្តរប្រវេសន៍ និងគួរផ្តល់ប្រព័ន្ធបញ្ជូនទៅឲ្យសេវាឯទៀតដែលពលករទេសន្តរប្រវេសន៍ត្រូវការ។ មណ្ឌលធនធានជនទេសន្តរប្រវេសន៍ដែលធ្វើប្រតិបត្តិការដោយរដ្ឋាភិបាល អង្គការនិយោជក អង្គការកម្មករ និងអង្គការសង្គមស៊ីវិលគួរផ្តល់សេវាគាំទ្រ និងកិច្ចការពារលើការដ្ឋានសំរាប់ពលករទេសន្តរប្រវេសន៍ និងត្រូវឲ្យមានការសម្របសម្រួលឲ្យបានល្អក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។

៨. គួរបង្កើតឲ្យមានប្រព័ន្ធបញ្ជូនរវាងប្រទេសដើម និងប្រទេសទីដៅ និងត្រូវមានដំណើរការល្អហើយត្រូវផ្តល់ជំនួយនៃស្ថានទូតដើម្បីធានាឲ្យមានការទូទាត់សំណងយ៉ាងត្រឹមត្រូវ និងផ្តល់អត្ថប្រយោជន៍ដល់ពលករទេសន្តរប្រវេសន៍យ៉ាងទាន់ពេលរួមមានការថែទាំសុខភាព និងការព្យាបាលរយៈពេលវែងលើជម្ងឺ និងរបួសដោយសារការងារ ទោះបីបន្ទាប់ពីពួកគេបានមកប្រទេសកំណើតហើយវិញក្តី។ គួរធ្វើការសិក្សាថ្នាក់តំបន់មួយជាមួយភាគីពាក់ព័ន្ធទាំងអស់ដើម្បីរកបញ្ហាប្រឈម និងគម្លាតគោលនយោបាយនៃការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ដែលពិការនៅពេលពួកគេមកដល់ប្រទេសកំណើតវិញ។

៩. អនុព័ន្ធការងារគួរទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងមានការគាំទ្រគ្រប់គ្រាន់ដើម្បីផ្តល់ការគាំពារយ៉ាងមានប្រសិទ្ធិភាពនៅលើការដ្ឋាន។ គួរមានតុល្យភាពយេនឌ័រក្នុងចំណោមអនុព័ន្ធការងារតាមសមមាត្រនៃពលករទេសន្តរប្រវេសន៍ជាស្ត្រី និងបុរស។

១០. ទីភ្នាក់ងារជ្រើសរើសគួរមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរក្សាកញ្ចប់អត្ថប្រយោជន៍ និងប្រាក់បំណាច់កាន់តែប្រសើរឡើងរបស់ពលករទេសន្តរប្រវេសន៍ រួមមានការកាត់បន្ថយ ឬលុបបំបាត់ថ្លៃឈ្នួលដែលគិតលើពលករទេសន្តរប្រវេសន៍។

១១. គួរចាត់វិធានការដើម្បីសម្របសម្រួលឲ្យពលករទេសន្តរប្រវេសន៍ទាំងស្ត្រី និងបុរសចូលរួមសហជីព និងសមាគម ជាពិសេសសំរាប់ពលករក្នុងវិស័យដែលពលករមិនបានរៀបចំ។

១២. គួរផ្តល់ការគាំទ្រដល់ពលករដែលដាក់ពាក្យបណ្តឹងឲ្យបានស្នាក់នៅក្នុងប្រទេសទីដៅនៅពេលដែលបណ្តឹងកំពុងស្ថិតក្នុងដំណើរការតុលាការ។ ដូច្នេះគួរផ្តល់ជំនួយយ៉ាងសមស្របនិងទាន់ពេលដល់ពលករទេសន្តរប្រវេសន៍ និងអ្នកតំណាងពលករទេសន្តរប្រវេសន៍ ពោលគឺការពារពួកគេឲ្យរួចផុតពីការសងសឹកពីនិយោជកក្នុងអំឡុងពេលដំណើរការពាក្យបណ្តឹង។

**បង្កើតគោលនយោបាយ និងនីតិវិធីដើម្បីសម្របសម្រួលទិដ្ឋភាពទេសន្តរប្រវេសន៍របស់ពលករ រួមមានការជ្រើសរើស ការរៀបចំដើម្បីការបញ្ជូនទៅបរទេស ការការពារពលករទេសន្តរប្រវេសន៍នៅពេលធ្វើការនៅបរទេស និងការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មក្នុងប្រទេសដើម។**

១៣. អង្គការនិយោជក និងអង្គការកម្មករដោយសហការណ៍យ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលគួរចូលរួមតាមរយៈការចរចារជាស្ថាប័នក្នុងការបង្កើត ការអនុវត្តន៍ ការធ្វើវិសោធនៈកម្ម និង/ឬការពិនិត្យឃ្លាំមើលគោលនយោបាយ និងកម្មវិធីទេសន្តរប្រវេសន៍ការងារដែលឆ្លើយតបនឹងយេនឌ័រក្នុងរដ្ឋជាសមាជិតអាស៊ាន។

១៤. ច្បាប់ជាតិ គោលនយោបាយ វិធាន និងបទបញ្ញត្តិពាក់ព័ន្ធនឹងការងារ និងការធ្វើទេសន្តរប្រវេសន៍ការងារគួរផ្តល់ព័ត៌មាន និងផ្សព្វផ្សាយយ៉ាងជាក់លាក់ដល់ពលករទេសន្តរប្រវេសន៍ទាំងស្ត្រី និងបុរស អង្គការកម្មករ និងអង្គការនិយោជក និងភាគីពាក់ព័ន្ធឯទៀត។ ជាពិសេសដោយមានការជួយគាំទ្រពីអនុព័ន្ធការងារ និងស្ថានទូត គួរផ្សព្វផ្សាយ ឲ្យទូលំទូលាយដល់ពលករទេសន្តរប្រវេសន៍អំពីព័ត៌មានការធ្វើទេសន្តរប្រវេសន៍ និងនីតិវិធីដាក់ពាក្យសុំទិដ្ឋាការ។

១៥. គួរបង្កើតគោលនយោបាយ និងនីតិវិធីជ្រើសរើសយ៉ាងមានប្រសិទ្ធិភាព ហើយត្រូវផ្សព្វផ្សាយដល់ពលករទេសន្តរប្រវេសន៍ និងភាគីពាក់ព័ន្ធទាំងអស់ ពោលគឺតាមរយៈសេវាច្រកចេញចូលតែមួយ និងមណ្ឌលធនធានជនទេសន្តរប្រវេសន៍នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។

១៦. គួរអនុវត្តកម្មវិធីអប់រំណែនាំតម្រង់ទិសមុនពេលចេញដំណើរ និងក្រោយពេលមកដល់ ជាកាតព្វកិច្ច និងមិនគិតថ្លៃលើពលករទេសន្តរប្រវេសន៍ទាំងស្ត្រី និងបុរស។ ឲ្យភាគីពាក់ព័ន្ធទាំងអស់ចូលរួម និងត្រូវបន្តកែលំអរគុណភាពកម្មវិធី ហើយត្រូវបញ្ចូលការណែនាំអំពីវប្បធម៌ និងសិទ្ធិ និងភារៈកិច្ចនៃពលករទេសន្តរប្រវេសន៍ទាំងស្ត្រី និងបុរស និងនិយោជក។

១៧. គួរផ្តល់ដំណឹង និងជំនួយដល់គ្រួសារពលករទេសន្តរប្រវេសន៍ដើម្បីឲ្យពួកគេអាចទប់ទល់ជាមួយបញ្ហាប្រឈមនៃការងារនៅក្រៅប្រទេស។

១៨. គួរផ្តល់កម្មវិធីគាំទ្រ រួមមានការប្រឹក្សាអំពីការងារ ការអភិវឌ្ឍន៍ជំនាញតាមទីផ្សារ និង/ឬការបណ្តុះបណ្តាលភាពជាសហគ្រិនដល់ពលករដែលត្រឡប់មកវិញ ហើយឯកសារបញ្ជាក់ពីបទពិសោធន៍ និងសមត្ថភាពដែលផ្តល់ដោយនិយោជកគួរត្រូវណែនាំឲ្យគេបានដឹង ដើម្បីផ្តល់ឱកាសការងារកាន់តែប្រសើរសំរាប់ពលករទេសន្តរប្រវេសន៍ទាំងស្ត្រី និងបុរសនៅក្នុងប្រទេសកំណើតរបស់ខ្លួន។

១៩. គួរពង្រឹងសហប្រតិបត្តិការរវាងប្រទេសដើម និងប្រទេសទទួលដើម្បីផ្តល់ជំនួយដល់ពលករទេសន្តរប្រវេសន៍ផ្នែកសុខភាពដើម្បីធានាឲ្យមានការទទួលបានការព្យាបាល និងសេវាសុខុមាលភាពសង្គម។

២០. អង្គការកម្មករក្នុងរដ្ឋជាសមាជិកអាស៊ានគួរពង្រឹងសហប្រតិបត្តិការរបស់ខ្លួនដើម្បីឲ្យមានយន្តការគាំពារពលករទេសន្តរប្រវេសន៍យ៉ាងមានប្រសិទ្ធិភាព។

អ្នកចូលរួមទាំងអស់បានសំដែងអំណរគុណដល់រដ្ឋាភិបាលនៃសាធារណៈរដ្ឋសហភាពមីយ៉ានម៉ា ជាពិសេសក្រសួងការងារ មុខរបរ និងសន្តិសុខសង្គមដែលបានរៀបចំវេទិការនេះ និងដែលបានផ្តល់ការទទួលយ៉ាងរាក់ទាក់ដល់ពួកគេ។

អ្នកចូលរួមក៏បានអបអរសាទរផងដែលចំពោះរដ្ឋាម៉ាឡេស៊ីដែលនឹងប្រកាន់យកតួនាទីជាប្រធានអាស៊ាននៅឆ្នាំ២០១៥ ហើយបានសំដែងអំណរគុណចំពោះការប្តេជ្ញាចិត្តរបស់ខ្លួនធ្វើជាម្ចាស់ផ្ទះរៀបចំវេទិការអាស៊ានលើកទី៨ស្តីពីទេសន្តរប្រវេសន៍ការងារនៅឆ្នាំក្រោយ។